**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលអនុក្រឹត្យលេខ៥៦ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៩៣ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា២ មាត្រា៣ និងមាត្រា៤ នៃអនុក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈ-កម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤ ស្តីពី បង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យហិរញ្ញវត្ថុ

- បានឃើញ អនុក្រឹត្យលេខ ៥៦ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ
- យោងតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រាមួយ.-**

មាត្រា៣ថ្មី មាត្រា៥ និងមាត្រា៧ នៃអនុក្រឹត្យលេខ ៥៦ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ ត្រូវបានធ្វើការកែសម្រួល ដូចខាងក្រោម÷

**មាត្រា៣ ថ្មី (មួយ).-**

**គ.ម.ហ.** មានសមាសភាព ដូចខាងក្រោម÷

| | | |
|---|---|---|
| ១. | ទេសាភិបាលធនាគារជាតិនៃកម្ពុជា | ប្រធាន |
| ២. | ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា | អនុប្រធានប្រចាំការ |
| ៣. | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥. | តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ៦. | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧. | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៨. | តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៩. | តំណាងក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ១០. | តំណាងក្រសួងកិច្ចការនារី | សមាជិក |
| ១១. | តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១២. | តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | សមាជិក |
| ១៣. | អគ្គលេខាធិការ ធនាគារជាតិនៃកម្ពុជា | លេខាធិការ |
| ១៤. | អគ្គនាយក នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១៥. | តំណាងធនាគារអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៦. | តំណាងសមាគមធនាគារនៅកម្ពុជា | សមាជិក |
| ១៧. | តំណាងសមាគមស្ថាប័នមីក្រូហិរញ្ញវត្ថុកម្ពុជា | សមាជិក |
| ១៨. | តំណាងសហគមន៍អភិវឌ្ឍន៍កសិកម្ម | សមាជិក |

សមាសភាពជាក់ស្តែងនៃ **គ.ហ.ម.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៥ ថ្មី.-**

**គ.ម.ហ** មានរបបប្រជុំសាមញ្ញ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ព្រមទាំងអាចប្រជុំជាវិសាមញ្ញ តាមការចាំបាច់។

សមាសភាពនៃ **គ.ម.ហ** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានត្រូវកោះអញ្ជើញ និងដឹកនាំប្រជុំ **គ.ម.ហ** តាមការប្រគល់សិទ្ធិរបស់ប្រធាន។

**គ.ម.ហ** មានសិទ្ធិប្រើប្រាស់ត្រារបស់ធនាគារជាតិនៃកម្ពុជាសម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា៧ ថ្មី.-**

**គ.ម.ហ** មានលេខាធិការដ្ឋានមួយនៅធនាគារជាតិនៃកម្ពុជា ជាសេនាធិការ ក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន។

ការរៀបចំ និងការប្រព្រឹត្តិទៅនៃលេខាធិការដ្ឋាន **គ.ម.ហ** ត្រូវបានកំណត់ដោយប្រកាសរបស់ទេសាភិបាលធនាគារជាតិនៃកម្ពុជា ដែលជាប្រធាន **គ.ម.ហ** ។

**មាត្រា២.-**

អនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៥ ស្តីពី ការកែសម្រួលមាត្រា៣ នៃអនុក្រឹត្យលេខ៥៦ អនក្រ.បក ស្តីពី ការបង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ និងបទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០១៧

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ